**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**
No. [illegible] MOC / SM 2008

# ប្រកាស

## ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ នាយកដ្ឋានដោះស្រាយវិវាទ និងគោលនយោបាយទូទៅ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៩អនក្រ.បក ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការដំឡើងនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ ( កាំកុងត្រូល ) ឱ្យទៅជាអគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ ( កាំកុងត្រូល ) ចំណុះក្រសួងពាណិជ្ជកម្ម
- យោងតាមការចាំបាច់របស់ក្រសួង

## <u>សម្រេច</u>

<u>**ប្រការ១**</u> : **នាយកដ្ឋានដោះស្រាយវិវាទ និងគោលនយោបាយទូទៅ** ស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំផ្ទាល់របស់អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ ( កាំកុងត្រូល ) មានតួនាទី និងភារកិច្ចដូចតទៅ ៖-

- រៀបចំ គ្រប់គ្រង និងថែរក្សាសំណុំលិខិតរបស់មន្ត្រីរាជការក្នុងអគ្គនាយកដ្ឋាន
- រៀបចំកម្មវិធីបណ្តុះបណ្តាល
- សម្របសម្រួលការងារផ្ទៃក្នុងអគ្គនាយកដ្ឋានជាមួយអង្គការក្រៅ និងសាខាចំណុះ
- គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលរបស់អគ្គនាយកដ្ឋាន និងឯកសារពាក់ព័ន្ធ
- គ្រប់គ្រងចលនទ្រព្យ និងឯកសារសារពើភ័ណ្ឌ



ក្រសួងពាណិជ្ជកម្ម
២០ A & B មហាវិថីព្រះនរោត្តម
ភ្នំពេញ ១២២០៥
ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨២៧ ៣៥៨ / ២១៨ ៩៨៦
ទូរសារលេខ: (៨៥៥) ២៣-២១៣-២៨៨ / ៩៩១-៧០៨
អ៊ីម៉ែល : moccabdir@yahoo.com

- រៀបចំ គ្រប់គ្រង និងដំណើការការងារគណនេយ្យ ហិរញ្ញវត្ថុក្នុងអគ្គនាយកដ្ឋាន
- រួមពិនិត្យសេចក្តីព្រាងច្បាប់ បញ្ញត្តិបច្ចេកទេសពាក់ព័ន្ធនឹងផលិតផល
- ផ្តល់មតិលើទិដ្ឋភាពច្បាប់ លើការបកស្រាយច្បាប់
- ពិនិត្យផ្នែកច្បាប់ លើការប្តឹងផ្តល់ទាំងឡាយទាក់ទងទៅនឹងគុណភាព សុវត្ថិភាព និងការក្លែងបន្លំ
- ធ្វើរបាយការណ៍សកម្មភាពរបស់អគ្គនាយកដ្ឋាន បូកសរុបស្ថិតិ
- កសាងព្រឹត្តិប័ត្រព័តិមានពាក់ព័ន្ធនឹងអគ្គនាយកដ្ឋាន
- ទំនាក់ទំនងជាមួយនឹងប្រព័ន្ធផ្សាយព័តិមាន
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

**ប្រការ២** : នាយកដ្ឋានដោះស្រាយវិវាទ និងគោលនយោបាយទូទៅ មានការិយាល័យចំណុះចំនួន ៤ ៖-

១-ការិយាល័យគណនេយ្យ ហិរញ្ញវត្ថុ
២-ការិយាល័យរដ្ឋបាល បុគ្គលិក និងបណ្តុះបណ្តាល
៣-ការិយាល័យគោលនយោបាយទូទៅ
៤-ការិយាល័យដោះស្រាយវិវាទ និងកិច្ចការច្បាប់
ការិយាល័យនីមួយៗដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនតាមការចាំបាច់ ។

**ប្រការ៣** : **ការិយាល័គណនេយ្យ ហិរញ្ញវត្ថុ** ទទួលបន្ទុក :

- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ និងឯកសារសារពើភ័ណ្ឌ
- រៀបចំ និងដំណើរការការងារគណនេយ្យហិរញ្ញវត្ថុក្នុងអគ្គនាយកដ្ឋាន
- អនុវត្តភារកិច្ចពាក់ព័ន្ធផ្សេងៗទៀតដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន ។

**ប្រការ៤** : **ការិយាល័យរដ្ឋបាល បុគ្គលិក និងបណ្តុះបណ្តាល** ទទួលបន្ទុក :

- រៀបចំ គ្រប់គ្រង និងថែរក្សាសំណុំលិខិតរបស់មន្ត្រីរាជការក្នុងអគ្គនាយកដ្ឋាន
- រៀបចំកម្មវិធីបណ្តុះបណ្តាល
- សម្របសម្រួលការងារផ្ទៃក្នុងអគ្គនាយកដ្ឋានជាមួយអង្គភាពខាងក្រៅ និងសាខាចំណុះ
- គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលរបស់អគ្គនាយកដ្ឋាន និងឯកសារពាក់ព័ន្ធ
- អនុវត្តភារកិច្ចពាក់ព័ន្ធផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន ។

**ប្រការ៥** : **ការិយាល័យគោលនយោបាយទូទៅ** ទទួលបន្ទុកៈ

- ធ្វើរបាយការណ៍សកម្មភាពរបស់អគ្គនាយកដ្ឋាន
- រៀបចំការងារស្ថិតិ និងបូកសរុបទូទាំងអគ្គនាយកដ្ឋាន
- កសាងព្រឹត្តិប័ត្រព័តិមានពាក់ព័ន្ធនឹងអគ្គនាយកដ្ឋាន
- ទំនាក់ទំនងជាមួយប្រព័ន្ធផ្សាយព័តិមាន
- អនុវត្តភារកិច្ចពាក់ព័ន្ធផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន ។



ក្រសួងពាណិជ្ជកម្ម
២០ A & B មហាវិថីព្រះនរោត្តម
ភ្នំពេញ ១២២០៥
ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៤២៧ ៣៥៨ / ២១៤ ៩៤៦
ទូរសារលេខ: (៨៥៥) ២៣-២១៣-២៤៨ / ៩៩១-៧០៨
អ៊ីម៉ែល : moccabdir@yahoo.com

**ប្រការ៦** : **ការិយាល័យដោះស្រាយវិវាទ និងកិច្ចការច្បាប់** ទទួលបន្ទុកៈ

- រួមពិនិត្យសេចក្តីព្រាងច្បាប់ បញ្ញត្តិបច្ចេកទេសពាន់ព័ន្ធ នឹងផលិតផល
- ផ្តល់មតិលើទិដ្ឋភាពច្បាប់ លើការបកស្រាយច្បាប់
- ពិនិត្យកិច្ចការផ្នែកច្បាប់ លើការប្តឹងផ្តល់ទាំងឡាយទាក់ទងនឹងគុណភាព សុវត្ថិភាព និងការក្លែងបន្លំ
- អនុវត្តភារកិច្ចពាក់ព័ន្ធផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន ។

**ប្រការ៧** : នាយិកាខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានគ្រប់អង្គភាពចំណុះក្រសួង ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ២០០៨

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**កន្លែងទទួល :**

-ដូចប្រការ៧

-ឯកសារ-កាលប្បវត្តិ



ក្រសួងពាណិជ្ជកម្ម
២០ A & B មហាវិថីព្រះនរោត្តម
ភ្នំពេញ ១២២០៥
ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨២៧ ៣៥៨ / ២១៨ ៩៨៦
ទូរសារលេខ: (៨៥៥) ២៣-២១៣-២៨៨ / ៩៩១-៧០៨
អ៊ីមែល : moccabdir@yahoo.com